# គណៈកម្មការដើម្បីសិទ្ធិបោះឆ្នោតរបស់ខ្មែរនៅក្រៅប្រទេស

**COMMISSION FOR ELECTION RIGHTS OF OVERSEAS CAMBODIANS (CEROC)**

**Email:** petition@khmeroversea.info, www.khmeroversea.info

THE CEROC

**MR. SOPHOAN P. SENG**
**Campaign Team Leader**

**MR. ARTHUR S. SUN**
**Member**

**MR. KOVID HO**
**Member**

**MR. SAMRACH CHHIM**
**Member**

**MRS. JANET SENG**
**Member**

**MR. CHANVEASNA OU**
**Member**

July 24, 2014

## សេចក្ដីថ្លែងការ

គណៈកម្មការដើម្បីសិទ្ធិបោះឆ្នោតរបស់ខ្មែរនៅក្រៅប្រទេសមានកិត្តិយសសូមថ្លែងនូវសេចក្ដីសង្ឃឹមនិងសុទិដ្ឋិនិយមដល់យន្តការដំណោះស្រាយនយោបាយទាំង៧ចំណុចដែលបានព្រមព្រៀងនិងចុះហត្ថលេខានៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤រវាងថ្នាក់ដឹកនាំកំពូលគណបក្សសង្គ្រោះជាតិខ្មែរនិងគណបក្សប្រជាជនកម្ពុជា។ ថ្វីត្បិតតែការព្រមព្រៀងពុំទាន់យកទៅអនុវត្តអោយបានជាផ្លែផ្កាក៏ដោយ ក៏យើងជឿជាក់ទៅលើឆន្ទៈថ្នាក់ដឹកនាំក្នុងការខិតខំប្រឹងប្រែងនាំមកនូវលទ្ធិប្រជាធិបតេយ្យនិងនីតិរដ្ឋពិតប្រាកដមកជូនប្រជាជនខ្មែរជាពិសេសគឺការរៀបចំបោះឆ្នោតមួយដ៏ទូលំទូលាយដោយបានរួមបញ្ចូលខ្មែរដែលរស់នៅនិងមានវត្តមាននៅបរទេសអាចអោយពួកគេមានសិទ្ធិបោះឆ្នោតផងដែរ។ ភាពប្រាកដនិយមនេះគឺដើរទន្ទឹមនឹងសារថ្លែងការណ៍របស់សហគមអ៊ឺរ៉ុប អង្គការសហប្រជាជាតិ សហរដ្ឋអាមេរិក ប្រទេសជប៉ុន និងប្រទេសបារាំងជាដើម។

គណៈកម្មការដើម្បីសិទ្ធិបោះឆ្នោតរបស់ខ្មែរនៅក្រៅប្រទេស The CEROC និងខិតខំបំពេញការងាររបស់ខ្លួន ព្រមទាំងបន្តការតាមដានបន្តទៅទៀត ដើម្បីធានាថាសិទ្ធិដែលមិនអាចដកហូតបានរបស់យើងក្នុងនាមជាពលរដ្ឋខ្មែរក្នុងការចូលរួមបោះឆ្នោតនូវរាល់ការបោះឆ្នោតជាតិរបស់កម្ពុជាមិនត្រូវបានគេបំពាន។ ដើម្បីសហការជាមួយមជ្ឈដ្ឋានដៃគូទាំងអស់ធ្វើអោយប្រាកដថាគ្មានប្រជាជនខ្មែរណាម្នាក់ត្រូវបានគេដកសិទ្ធិចេញពីការចូលរួមបដិបត្តិពេញលេញ ទាំងការចូលរួមការអភិវឌ្ឍន៍ផ្នែកសង្គម សេដ្ឋកិច្ច និង នយោបាយនៅក្នុងប្រទេសកម្ពុជា។ ដើម្បីជួយពង្រឹងការអនុវត្តន៍តាមរដ្ឋធម្មនុញ្ញជាតិកម្ពុជានិងសេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។

**សេង សុភ័ណ**

មេដឹកនាំយុទ្ធនាការ

Tel: (403) 455-8294
Email: petition@khmeroversea.info

Commission for Election Rights of Overseas Cambodians (CEROC)
Contact: PO Box #554, 2949 – 17th Ave. SE, Calgary, AB T2A 0P7, Canada
Tel: 403-455-8294, Email: petition@khmeroversea.info